ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តាងនាមប្រជារាស្ត្រខ្មែរ
សាលាដំបូងរាជធានីភ្នំពេញ

សាលាដំបូងរាជធានីភ្នំពេញ
សាលក្រមព្រហ្មទណ្ឌលេខ: ៥០៤ "វ"
ចុះថ្ងៃទី ១៤.០២.២០២៤
-សំណុំរឿងព្រហ្មទណ្ឌលេខ ៤១០០
ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៣
-លេខបង្គាប់ឱ្យកោះ ២៩៩៩
ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០២៣
-ជំនុំជម្រះលេខ ៥៥២៩
ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២៣

បានបើកសវនាការជំនុំជម្រះជាសាធារណៈ នៅសាលាដំបូងរាជធានីភ្នំពេញ នាថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៤ វេលាម៉ោង ០៨ : ០០ នាទីព្រឹក ដោយមានសមាសភាពចូលរួមដូចតទៅ:

ចៅក្រមជំនុំជម្រះ

-លោកស្រី [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារង អមសាលាដំបូងរាជធានីភ្នំពេញ

ក្រឡាបញ្ជីសវនាការ

-លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៤១០០ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៣ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] NG YONG QING ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិសិង្ហបុរី មុខរបរ បុគ្គលិកក្រុមហ៊ុន កាន់លិខិតឆ្លងដែនលេខ K2214462K ទីកន្លែងកំណើតនៅ [redacted] ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅសណ្ឋាគារNAGA2 សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ [redacted] WONG មានកូន ០១នាក់ ឪពុកឈ្មោះ [redacted] SUEE LIN "រស់" ម្តាយមិនស្គាល់ឈ្មោះ "ស្លាប់" ជាទីតិជន ប្រវត្តិផ្តន្ទាទោសដោយតុលាការ-គ្មាន។

-តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៦១៤៨ "ក" ដ.ឃ.ដ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០២៣។ (ម១)

ជាប់ចោទពីបទ: **អនោក** ប្រព្រឹត្តនៅចំណុចសណ្ឋាគារNAGA2 បន្ទប់លេខ១២២៩ ជាន់ទី១២ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ និងថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ។

២-ឈ្មោះ [redacted] DAO QIANG ភេទប្រុស អាយុ៤៤ឆ្នាំ ជនជាតិចិន មុខរបរ បុគ្គលិកកាស៊ីណូ កាន់លិខិតឆ្លងដែនលេខ EJ7987908 ទីកន្លែងកំណើតនៅ [redacted] ទីលំនៅបច្ចុប្បន្នស្នាក់នៅសណ្ឋាគារ NAGA2 សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ [redacted] XIAO QIN មានកូន ០២នាក់ ឪពុកឈ្មោះ [redacted] MAO "រស់" ម្តាយឈ្មោះ [redacted] YUE YUN "រស់" ជាទីតិជន ប្រវត្តិផ្តន្ទាទោសដោយតុលាការ-គ្មាន។

-តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៦១៤៩ "ក" ដ.ឃ.ដ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០២៣។ (ម១)

-ដីកាសម្រេចអោះលែងឱ្យនៅក្រៅឃុំលេខ ៧៥៤២ "ក" ដ.ព.ស ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៣។

-ដីកាបង្គាប់ឱ្យអោះលែងលេខ ៩៦៨០ "ក" ដ.ព.ស ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៣។

Scanned with CamScanner

-ដីកាសម្រេចដាក់ជនត្រូវចោទស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការលេខ ៧៥៤៣ "ភ" ដ.ព.ស ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៣។

៣-ឈ្មោះ [redacted] BIN ភេទប្រុស អាយុ៣៩ឆ្នាំ ជនជាតិចិន មុខរបរ បុគ្គលិកកាស៊ីណូ កាន់លិខិតឆ្លងដែនលេខ EJ7201025 ទីកន្លែងកំណើតនៅប្រទេសចិន ទីលំនៅបច្ចុប្បន្នស្នាក់នៅសណ្ឋាគារNAGA2 សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] XIAO "រស់" ម្តាយឈ្មោះ [redacted] HONG "រស់" នៅលីវ ជានីតិជន ប្រវត្តិផ្តន្ទាទោសដោយតុលាការ-គ្មាន ។

-តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៦១៤៧ "ភ" ដ.ឃ.ដ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០២៣។(ម១)

-ដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំលេខ ៧៥៤០ "ភ" ដ.ព.ស ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៣។

-ដីកាបង្គាប់ឱ្យដោះលែងលេខ ៩៦៧៩ "ភ" ដ.ព.ស ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៣។

-ដីកាសម្រេចដាក់ជនត្រូវចោទស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការលេខ ៧៥៤១ "ភ" ដ.ព.ស ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០២៣។

ជាប់ចោទពីបទ: **ចាប់បង្ខាំងមនុស្សដោយខុសច្បាប់** ប្រព្រឹត្តនៅចំណុចសណ្ឋាគារNAGA2 បន្ទប់លេខ១២២៩ ជាន់ទី១២ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ និងថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា២៥៣ នៃក្រមព្រហ្មទណ្ឌ។

-មានអ្នកបកប្រែភាសាចិនឈ្មោះ [redacted] ស្រីពេជ្រ នៃសាលាដំបូងរាជធានីភ្នំពេញ។

អង្គហេតុនៃរឿងហានដូចតទៅ:

កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ កម្លាំង(HOTLINE)ជាមួយជនបរទេសនៃនាយកដ្ឋានចារកម្មនៃអគ្គស្នងការដ្ឋាននគរបាលជាតិ បានទទួលបណ្តឹងតាមទូរស័ព្ទមកក្រុមការងារ CNP-GDI-FBI-Task Force ពីក្រុមគ្រួសារជនរងគ្រោះឈ្មោះ [redacted] NG YONG QING ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិសិង្ហបុរី សង្ស័យចាប់ជំរិតនៅប្រទេសកម្ពុជា។ សមត្ថកិច្ចបានសហការជាមួយកម្លាំងមូលដ្ឋានល្បែងពាណិជ្ជកម្ម នៃអគ្គស្នងការដ្ឋាននគរបាលជាតិ បានចុះស្រាវជ្រាវ និងកំណត់ទីតាំងនៅសណ្ឋាគារNAGA2 បន្ទប់លេខ១២២៩ ជាន់ទី១២ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ នៅវេលាម៉ោង ១០ និង ០០នាទីយប់។ សមត្ថកិច្ចបានរកឃើញឈ្មោះ [redacted] NG YONG QING ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិសិង្ហបុរី ឈ្មោះ [redacted] BIN ភេទប្រុស អាយុ៣៩ឆ្នាំ ជនជាតិចិន និងឈ្មោះ [redacted] DAO QIANG ភេទប្រុស អាយុ៤៣ឆ្នាំ ជនជាតិចិន និងធ្វើការឃាត់ខ្លួនតែម្តង។ នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៣ ឈ្មោះ [redacted] NG YONG QING បានមកប្រទេសកម្ពុជាជាមួយមិត្តភក្តិចំនួន ០២នាក់ឈ្មោះ [redacted] KIM YONG ភេទប្រុស ជនជាតិសិង្ហបុរី និងឈ្មោះ [redacted] OH ភេទប្រុស ជនជាតិសិង្ហបុរី ដើម្បីមកលេងល្បែងកាស៊ីណូហាវអ៊ីនឡាយ ក្នុងសណ្ឋាគារNAGA2 តាមរយៈការណែនាំមិត្តភក្តិឈ្មោះ ZACK ភេទប្រុស ជនជាតិសិង្ហបុរី ចំណែកឈ្មោះ EARNEST ភេទប្រុស ជនជាតិសិង្ហបុរី មិនបានមកលេងជាមួយទេ។ ឈ្មោះ [redacted] NG YONG QING បានបង្ហាញគណនី Cripto (ប្រព័ន្ធប្រាក់អេឡិចត្រូនិក) ដែលមានប្រាក់ ចំនួន ៤៥.១៣២,១៨ USTD ដែលជារបស់ឈ្មោះ EARNEST រួចខ្លួនក៏ខ្ចីកាក់ចំនួន ១០កាក់ ស្មើនឹង ៥០.000 (ប្រាំម៉ឺន) អុណ្ណរអាមេរិក និងធ្វើកិច្ចសន្យាខ្ចីប្រាក់ជាមួយក្រុមហ៊ុនឈ្មោះ [redacted] Zuan Loan & Pawn Co.,LTD ក្នុងករណីលេងល្បែងចាញ់នឹងទូទាត់ជាមួយគណនី Cripto របស់គេ។ បន្ទាប់ពីលេងល្បែងចាញ់ប្រាក់អស់ហើយឈ្មោះ [redacted] KIM YONG និងឈ្មោះ [redacted] OH បាននាំគ្នារត់គេចខ្លួន ចំណែកឯឈ្មោះ [redacted] NG YONG QING រត់មិនរួចក៏ត្រូវខាងក្រុមហ៊ុនឃាត់ខ្លួនព្រោះជាអ្នកឈរ

Scanned with CamScanner

ឈ្មោះខ្ចីប្រាក់ ទើបភាគីក្រុមហ៊ុននាំឈ្មោះ [redacted] NG YONG QING មកធ្វើការដោះស្រាយជាមួយគ្នានៅ Apartment ឈ្មោះ ថាន់សីមីងចឹង នៅទីក្រុងកោះពេជ្រ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។ លុះដល់ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ វេលាម៉ោងង ១៤ និង ០០នាទី ក្រុមហ៊ុននាំឈ្មោះ [redacted] NG YONG QING ទៅសណ្ឋាគារ NAGA2 បន្ទប់លេខ១២២៩ ជាន់ទី១២ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ដោយឲ្យឈ្មោះ [redacted] BIN ភេទប្រុស អាយុ ៣៩ឆ្នាំ ជនជាតិចិន និងឈ្មោះ [redacted] DAO QIANG ភេទប្រុស អាយុ៤៣ឆ្នាំ ជនជាតិចិន នៅរង់ចាំប្តឹរមើល និងព្យាយាមឲ្យឈ្មោះ BRIAN NG YONG QING ទាក់ទងទៅក្រុមគ្រួសាររកប្រាក់សងមកវិញ។ ប៉ុន្តែឈ្មោះ [redacted] BIN និងឈ្មោះ CHEN DAO QIANG បានអនុវត្តលើសគោលការណ៍របស់ក្រុមហ៊ុន ដោយបានបង្ខាំង និងបង្ខំឈ្មោះ [redacted] NG YONG QING ដើម្បីទារប្រាក់មកវិញឲ្យបានឆាប់រហ័ស។ បន្ទាប់មកសមត្ថកិច្ចក៏បានឃាត់ខ្លួនឈ្មោះ [redacted] NG YONG QING ឈ្មោះ [redacted] BIN និងឈ្មោះ [redacted] DAO QIANG រួមទាំងវត្ថុតាងយកមកសាកសួរតែម្តង។

-បានឃើញ៖របាយការណ៍លេខ ១០០៩/២០២៣ ន.ប.ក ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៣ របស់នាយកដ្ឋានចារកម្មនៃនាយកដ្ឋានកណ្តាលសន្តិសុខ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ។

-បានឃើញ៖ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ៣០៤៩ អ.ឃ.ជ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ៖ដីកាសន្និដ្ឋានស្តាពរលេខ ៤៥៣៩ អ.ឃ.ជ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ៖ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៥៧៦៤ "ភ" ដ.ដ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] NG YONG QING បានឆ្លើយថា: ខ្ញុំមិនមែនជាអ្នកប្តឹងសមត្ថកិច្ចនោះទេ។ ខ្ញុំបានប្រាប់ទៅឪពុករបស់ខ្ញុំនៅប្រទេសសិង្ហបុរីថាខ្ញុំត្រូវបានគេចាប់វាយទារប្រាក់ចំនួន ៥០.០០០(ប្រាំម៉ឺន)អុណ្ណារអាមេរិក ទើបឪពុកខ្ញុំប្តឹងសមត្ថកិច្ចនៅប្រទេសសិង្ហបុរីពីករណីនេះ។ ខ្ញុំត្រូវបានសមត្ថកិច្ចឃាត់ខ្លួននៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ នៅវេលាម៉ោងប្រហែល ២ ទៅ ៣ ភ្លឺ។ នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៣ ខ្ញុំបានទៅលេងល្បែងនៅណាហ្គា២ ជាមួយនឹងមិត្តភក្តិរបស់ខ្ញុំឈ្មោះ Tan Kim Yong និងឈ្មោះ Leonard oh។ ពេលនោះឈ្មោះ Earnest បានប្រាប់ខ្ញុំថា "បង្ហាញតែ USTD ទៅគេយកកាក់ល្បែងមកឲ្យខ្ញុំលេងហើយចំនួន ៥០.០០០(ប្រាំម៉ឺន)អុណ្ណារអាមេរិក។ ចំពោះ USTD ជា APP របស់ឈ្មោះ Earnest ហើយសព្វថ្ងៃនេះឈ្មោះ Earnest ស្នាក់នៅប្រទេសវៀតណាម។ ចំពោះកាក់ល្បែងដែលមានចំនួន ៥០.០០០(ប្រាំម៉ឺន)អុណ្ណារអាមេរិក គឺខ្ញុំបានលេងចាញ់អស់ហើយ។ ពេលនោះខាងកាស៊ីណូពុំមែនជាអ្នកទារប្រាក់ពីខ្ញុំទេ គឺមានជនជាតិចិនចំនួន០២នាក់ដែលសមត្ថកិច្ចឃាត់មកឲ្យខ្ញុំសរសេរលិខិតផ្តិតមេដៃជំពាក់ប្រាក់ចំនួន ៥០.០០០(ប្រាំម៉ឺន)អុណ្ណារអាមេរិក តែខ្ញុំមិនមានប្រាក់សងគេទេ។ ពេលនោះខ្ញុំរៀបដើរចេញពីកាស៊ីណូ ទើបជនជាតិចិនទាំងពីរនាក់នោះ បានឃាត់ខ្លួនខ្ញុំទារប្រាក់ចំនួន ៥០.០០០(ប្រាំម៉ឺន)អុណ្ណារអាមេរិក តែខ្ញុំពុំមានប្រាក់ឲ្យទើបគេឲ្យខ្ញុំទាក់ទងទៅអ្នកផ្ទះ ឬមិត្តភក្តិដើម្បីយកប្រាក់មកសងគេវិញ។ នៅពេលដែលគេចាប់ឃាត់ខ្លួនគឺគេមិនបានចងនោះទេ គ្រាន់តែវាយនឹងដៃតែប៉ុណ្ណោះ។

-តាមអំណាងចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] DAO QIANG បានឆ្លើយថា: ខ្ញុំ និងឈ្មោះ [redacted] BIN បានឃាត់ខ្លួនឈ្មោះ [redacted] NG YONG QING ពិតមែនដោយសារឈ្មោះ [redacted] NG YONG QING ជំពាក់ប្រាក់កាស៊ីណូ

Scanned with CamScanner

NAGA2 ចំនួន ៥0.000(ប្រាំម៉ឺន)អុណ្ណារអាមេរិក ដោយសារឈ្មោះ [redacted] NG YONG QING បានបង្ហាញគណនីមានទឹកប្រាក់ចំនួន ៤៥.000(ប្លនម៉ឺនប្រាំពាន់)អុណ្ណារអាមេរិក ទើបខាងកាស៊ីណូឲ្យឈ្មោះ [redacted] NG YONG QING ខ្ចីដល់ ចំនួន ៥0.000(ប្រាំម៉ឺន)អុណ្ណារអាមេរិក។ ពេលដែលឈ្មោះ [redacted] NG YONG QING លេងចាញ់អស់ ស្រាប់តែបាញ់ប្រាក់មិនចេញ ហើយព្យាយាមគេចខ្លួន ទើបពួកខ្ញុំឃាត់ឈ្មោះ [redacted] NG YONG QING ដើម្បីឲ្យឈ្មោះ [redacted] NG YONG QING សងប្រាក់មកខាងកាស៊ីណូវិញតែប៉ុណ្ណោះ។ ខ្ញុំឃាត់ខ្លួនឈ្មោះ [redacted] NG YONG QING មិនទាន់ដល់មួយថ្ងៃទេ ហើយក៏ពុំបានវាយដំធ្វើបាបឈ្មោះ [redacted] NG YONG QING ដែរ។ ពួកខ្ញុំមិនបានបង្ខាំង ឬចាប់បង្ខំឈ្មោះ [redacted] NG YONG QING ទេ។ ពួកខ្ញុំគ្រាន់តែមិនឲ្យឈ្មោះ [redacted] NG YONG QING ទៅណា និងឲ្យឈ្មោះ [redacted] NG YONG QING សហការទូរស័ព្ទទៅមិត្តភក្តិ ឬបងប្អូនដើម្បីយកប្រាក់មកសងកាស៊ីណូវិញតែប៉ុណ្ណោះ។ ខ្ញុំមិនបានប្រព្រឹត្តអ្វីដែលឈ្មោះ [redacted] NG YONG QING បានចោទប្រកាន់នោះទេ។

-តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] BIN បានឆ្លើយថា: ខ្ញុំ និងឈ្មោះ [redacted] DAO QIANG គឺជាបុគ្គលិករបស់ NAGA2 បានប្រាក់ខែចំនួន ១.៣00(មួយពាន់បីរយ)អុណ្ណារអាមេរិកក្នុងមួយខែ ហើយមូលហេតុដែលខ្ញុំឃាត់ខ្លួនឈ្មោះ [redacted] NG YONG QING ដោយសារឈ្មោះ [redacted] NG YONG QING ជំពាក់ប្រាក់កាស៊ីណូ២ចំនួន ៥0.000(ប្រាំម៉ឺន)អុណ្ណារអាមេរិក មិនព្រមសង ហើយបានព្យាយាមរត់គេចខ្លួនមិនទទួលខុសត្រូវ។ បានជាឈ្មោះ [redacted] NG YONG QING ខ្ចីប្រាក់ទៅលេងល្បែង ហើយខាងកាស៊ីណូឱ្យឈ្មោះ [redacted] NG YONG QING ខ្ចីប្រាក់ដោយសារឈ្មោះ [redacted] NG YONG QING បានបង្ហាញគណនីមានទឹកប្រាក់ចំនួន ៤៥.000$ ទើបខាងកាស៊ីណូ២ឱ្យឈ្មោះ [redacted] NG YONG QING ខ្ចីប្រាក់ចំនួន ៥0.000$។ ពេលដែលឈ្មោះ [redacted] NG YONG QING លេងល្បែងចាញ់អស់ ស្រាប់តែបាញ់ប្រាក់ចេញពីកុងនោះមិនបាន ហើយព្យាយាមគេចខ្លួន ទើបពួកខ្ញុំឃាត់ឈ្មោះ [redacted] NG YONG QING ដើម្បីឱ្យឈ្មោះ [redacted] NG YONG QING សងប្រាក់មកកាស៊ីណូវិញតែប៉ុណ្ណោះ។ ពួកខ្ញុំឃាត់ខ្លួនឈ្មោះ [redacted] NG YONG QING គឺពុំបានវាយដំ ឬឃុំឃាំង ឬធ្វើបាបឈ្មោះ [redacted] NG YONG QING ទេ។ ដូចនេះពួកខ្ញុំពុំបានចាប់បង្ខាំងឈ្មោះ [redacted] NG YONG QING ទេគឺគ្រាន់តែមិនឱ្យឈ្មោះ BRIAN NG YONG QING ទៅណាតែប៉ុណ្ណោះខ្លាចឈ្មោះ [redacted] NG YONG QING រត់គេចខ្លួនបាត់ពុំសងប្រាក់មកវិញតែប៉ុណ្ណោះ។ ម្យ៉ាងវិញទៀតពួកខ្ញុំបានសហការជាមួយឈ្មោះ [redacted] NG YONG QING ដើម្បីឱ្យឈ្មោះ [redacted] NG YONG QING ទូរស័ព្ទទៅមិត្តភក្តិ ឬបងប្អូនដើម្បីរកប្រាក់មកសងកាស៊ីណូវិញតែប៉ុណ្ណោះ ពុំមានបំណងអ្វីផ្សេងឡើយ។

-សាក្សីឈ្មោះ [redacted] ហុងងួន ជាមន្ត្រីនគរបាលយុត្តិធម៌បានបំភ្លឺថា: ឈ្មោះ [redacted] NG YONG QING អោទប្រុសនិងមិត្តភក្តិពីរនាក់ទៀតឈ្មោះ តាន់គីមឃុង និងឈ្មោះ អៀណេស ចូលមកប្រទេសកម្ពុជា ហើយបានចូលលេងល្បែងនៅណាហ្គា បើឈ្នះនឹងចែកភាគលាភចំនួន៥0%។ នៅលើកទីមួយនេះឈ្មោះ [redacted] NG YONG QING បានឈ្នះ និងបានត្រឡប់ទៅវិញ។ ក្រោយមកឈ្មោះ អៀណេស បានប្រាប់ទៅឈ្មោះ [redacted] NG YONG QING ឱ្យមកម្តងទៀត ដោយមកជាមួយបុគ្គលពីរនាក់ផ្សេងទៀត ហើយក៏បានមកដល់ប្រទេសកម្ពុជា ដោយប្រើគណនីគ្រីបតូដើម្បីខ្ចីប្រាក់ចំនួន ៥0.000$ ហើយបង្ហាញទៅខាងណាហ្គាគេឱ្យខ្ចីប្រាក់ហើយ។ នៅពេលនោះឈ្មោះ [redacted] NG YONG QING បានបង្ហាញគណនីទៅខាងណាហ្គាមើលគេក៏ឱ្យខ្ចី និងលេងល្បែងនៅណាហ្គាស្រាប់តែចាញ់អស់ ហើយបានទាក់ទងទៅឈ្មោះ អៀណេស ប៉ុន្តែទាក់ទងមិនបាន ហើយបានទាក់ទងទៅឈ្មោះ [redacted] ទៀត ស្រាប់តែឈ្មោះ ជែក បានប្រាប់ឈ្មោះ [redacted] NG YONG QING ឱ្យរត់ចេញទៅ។ ដល់ពេលរត់គេចខ្លួនស្រាប់តែមិត្តភក្តិពីរនាក់ទៀតបានរត់គេចខ្លួនបាត់ ហើយឈ្មោះ [redacted] NG

YONG QING ត្រូវបានខាងក្រុមហ៊ុនគេចាប់ខ្លួនជាប់។ បន្ទាប់មកខាងក្រុមហ៊ុនបានប្រាប់ទៅឈ្មោះ [redacted] NG YONG QING ឱ្យទាក់ទងទៅក្រុមគ្រួសារគាត់ តែបែរជាប្រាប់ថា គេចាប់ជំរិតគាត់ទៅវិញ។ ពេលសមត្ថកិច្ចចុះទៅដល់កន្លែងកើតហេតុនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ បាននាំខ្លួនឈ្មោះ [redacted] NG YONG QING មកសួរនាំ ទើបដឹងថា តាមពិតគាត់ចូលទៅលេងល្បែងនៅកាស៊ីណូលេងល្បែងចាញ់អត់មានលុយសង ហើយមិត្តភក្តិគាត់បានកុហស ទើបគាត់ព្យាយាមរត់គេចខ្លួន ហើយសមត្ថកិច្ចក៏បានចោទប្រកាន់ទៅលើឈ្មោះ [redacted] NG YONG QING ពីបទៈ ឆបោក ដែរ។ ចំពោះករណីចាប់បង្ខាំងមនុស្សដោយខុសច្បាប់វិញគឺពេលចុះទៅឈ្មោះ [redacted] NG YONG QING សម្ងំធម្មតា រីឯពីរនាក់ទៀតឈ្មោះ [redacted] BIN និងឈ្មោះ [redacted] DAO QIANG គេងនៅលើគ្រែធម្មតាព្រោះជាកន្លែងស្នាក់នៅ។ ដោយសារឈ្មោះ BRIAN NG YONG QING មានរបួស ហើយបានប្រាប់ថា មានគេវ៉ៃគាត់ ប៉ុន្តែឈ្មោះ [redacted] DAO QIANG បញ្ជាក់ថានៅពេលដែលឈ្មោះ [redacted] NG YONG QING រត់គេចខ្លួនគឺមានការប្រតាយប្រតប់គ្នាបានជាទៅមានរបួសស្នាម ហើយឈ្មោះ [redacted] NG YONG QING បានថតរបួសស្នាមនេះផ្ញើទៅក្រុមគ្រួសារខ្លួន ហើយប្រាប់ថា "មានការចាប់ជំរិតគាត់"។ ចំពោះរបួសស្នាមរបស់ឈ្មោះ [redacted] NG YONG QING នេះគឺកើតឡើងដោយសារមានការប្រតាយប្រតប់គ្នាខណៈពេលឈ្មោះ [redacted] NG YONG QING ព្យាយាមរត់គេចខ្លួន។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា: ក្រោយពីបានពិភាក្សាដេញដោលនាពេលសវនាការ និងស្តាប់ចម្លើយរបស់ជនជាប់ចោទទាំងពីរនាក់ទៀត រួចមកនូវអង្គហេតុខាងលើគឺជនជាប់ចោទពិតជាបានទទួលស្គាល់អង្គហេតុនេះមែន។ ដូចនេះតំណាងអយ្យការនៅតែគម្លល់ការចោទប្រកាន់ទៅលើជនជាប់ចោទ ដូចមាននៅក្នុងដីកាសន្និដ្ឋានស្តាពរលេខ ៤៥៣៩ អ.ឃ.ជ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៣ និងស្នើសុំឱ្យលោកស្រីចៅក្រមសម្រេចផ្តន្ទាទោសជនជាប់ចោទទាំងអស់តាមផ្លូវច្បាប់។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] DAO QIANG បានធ្វើសេចក្តីសន្និដ្ឋានថា: ពាក់ព័ន្ធនឹងករណីនេះ បន្ទាប់ពីពិភាក្សាសួរដេញដោលនាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] NG YONG QING និងមិត្តភក្តិគាត់ពីរនាក់ទៀតបានចូលលេងល្បែងណាហ្គា២។ បន្ទាប់ពីលេងចាញ់ល្បែងអស់ប្រាក់ហើយ ស្រាប់តែឈ្មោះ [redacted] NG YONG QING បានទូទាត់ប្រាក់ឱ្យទៅខាងណាហ្គា២ ស្រាប់តែនៅក្នុងគណនីគ្រីបតូរបស់គេមិនអាចទូទាត់បានទេ ហើយជនជាប់ចោទឈ្មោះ [redacted] NG YONG QING និងមិត្តភក្តិពីរនាក់ទៀតមានចេតនារត់គេច ប៉ុន្តែត្រូវកូនក្តីខ្ញុំទាំងពីរនាក់ចាប់ឈ្មោះ [redacted] NG YONG QING ជាប់។ នៅពេលដែលកូនក្តីខ្ញុំបាននាំឈ្មោះ [redacted] NG YONG QING ដើម្បីទៅបំពេញកាតព្វកិច្ច និងបានទាក់ទងទៅគ្រួសារដើម្បីឱ្យសងប្រាក់ចំនួន ៥០.០០០$ ដែលបានលេងល្បែងចាញ់នោះ ប៉ុន្តែបែរជាឈ្មោះ [redacted] NG YONG QING ប្រាប់ទៅក្រុមគ្រួសារគាត់ "ពីរឿងចាប់ជំរិតទៅវិញ"។ ជាក់ស្តែងកូនក្តីខ្ញុំបាទគឺគ្រាន់តែនាំគាត់ដើម្បីបំពេញកាតព្វកិច្ចក្នុងការសងប្រាក់ចំនួន ៥០.០០០$ តែប៉ុណ្ណោះ។ នៅក្នុងអង្គសវនាការសាក្សីជាមន្ត្រីនគរបាលយុត្តិធម៌ក៏បានបញ្ជាក់ផងដែរថា ជនជាប់ចោទនៅពេលចូលទៅណាហ្គា២ នៅក្នុងបន្ទប់លេខ ១២២៩ ជាន់ទី១២ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ជនជាប់ចោទឈ្មោះ [redacted] NG YONG QING ពុំមានការចាប់ចងអ្វីទេ គឺអង្គុយនៅលើសាឡុងជាធម្មតាជាមួយជនជាប់ចោទពីរនាក់ទៀតដែលជាកូនក្តីខ្ញុំបាទ។ ហេតុនេះកូនក្តីខ្ញុំទាំងពីរនាក់គ្រាន់តែចាប់ជនជាប់ចោទឈ្មោះ [redacted] NG YONG QING ឱ្យបំពេញកាតព្វកិច្ចដើម្បីឱ្យឈ្មោះ [redacted] NG YONG QING សងប្រាក់ ពុំមានចេតនាក្នុងការប្រព្រឹត្តបទល្មើសឡើយ។ យោងតាមបញ្ញត្តិមាត្រា ៤ នៃក្រមព្រហ្មទណ្ឌស្តីពីចេតនានៃការប្រព្រឹត្តបទល្មើសបានចែងថា "ពុំមានបទល្មើសទេបើសិនពុំមានចេតនាប្រព្រឹត្តបទល្មើស"។ ហេតុដូច្នេះក្នុងនាមខ្ញុំជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] BIN និងឈ្មោះ [redacted] DAO QIANG ស្នើសុំឱ្យលោកស្រីចៅក្រមជំនុំជម្រះមេត្តាពិចារណាសម្រេចឱ្យកូនក្តីខ្ញុំបាទ

Scanned with CamScanner

ឈ្មោះ [redacted] BIN និងឈ្មោះ [redacted] DAO QIANG រួចផុតបទចោទពីបទ: ចាប់បង្ខាំងមនុស្សដោយខុសច្បាប់ ប្រព្រឹត្តនៅចំណុចសណ្ឋាគារណាហ្គា២ បន្ទប់លេខ១២២៩ ជាន់ទី១២ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ និងថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ តាមបញ្ញត្តិមាត្រា ២៥៣ ក្រមព្រហ្មទណ្ឌ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] DAO QIANG និងឈ្មោះ [redacted] BIN បានធ្វើសេចក្តីសន្និដ្ឋានថា: ចំពោះសេចក្តីសន្និដ្ឋានសហភាគារបស់ខ្ញុំដែលបានលើកឡើងខាងលើនេះ គឺខ្ញុំឯកភាពទាំងស្រុង ហើយគ្រាន់តែចង់បញ្ជាក់បន្ថែមថា សកម្មភាពរបស់កូនក្តីខ្ញុំទាំងពីរនាក់ឈ្មោះ [redacted] BIN និងឈ្មោះ [redacted] DAO QIANG គឺធ្វើឡើងចង់ឱ្យឈ្មោះ [redacted] NG YONG QING បំពេញកាតព្វកិច្ចសងប្រាក់មកឱ្យខាងណាហ្គា២ វិញតែប៉ុណ្ណោះ។ ហេតុនេះស្នើសុំឱ្យលោកស្រីចៅក្រមជំនុំជម្រះមេត្តាសម្រេចឱ្យកូនក្តីខ្ញុំបាទរួចផុតពីបទ: ចាប់បង្ខាំងមនុស្សដោយខុសច្បាប់ ប្រព្រឹត្តនៅចំណុចសណ្ឋាគារណាហ្គា២ បន្ទប់លេខ១២២៩ ជាន់ទី១២ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ និងថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ តាមបញ្ញត្តិមាត្រា ២៥៣ នៃក្រមព្រហ្មទណ្ឌ។

-លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] NG YONG QING បានធ្វើសេចក្តីសន្និដ្ឋានថា: ដោយនៅក្នុងសំណុំរឿងនេះកូនក្តីនាងខ្ញុំបានធ្លើយសារភាព និងបានទទួលស្គាល់ការចូលទៅណាហ្គាវិល ដោយបានបង្ហាញនូវគណនីគ្រីបតូមានទឹកប្រាក់ចំនួន ៤៥.000$ ពិតប្រាកដមែន។ ប៉ុន្តែនៅពេលលេងអស់ប្រាក់ពីខ្លួនហើយចំនួន ៥0.000$ គឺកូនក្តីខ្ញុំមិនមានចេតនារត់គេចទេ ហើយគាត់ប្រាប់ថា នឹងសងប្រាក់នៅពេលដែលគាត់មានប្រាក់។ បន្ទាប់មកកូនក្តីខ្ញុំបានទាក់ទងទៅក្រុមគ្រួសារដើម្បីឱ្យផ្ញើប្រាក់មកកូនក្តីខ្ញុំដើម្បីសងប្រាក់ទៅខាងណាហ្គា២ ប៉ុន្តែមិនទាន់ឃើញក្រុមគ្រួសារគាត់ផ្ញើមក។ ហេតុនេះក្នុងនាមខ្ញុំជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] NG YONG QING ស្នើសុំឱ្យលោកស្រីចៅក្រមផ្តល់ស្ថានសម្រាលទោសដល់កូនក្តីនាងខ្ញុំដោយក្តីអនុគ្រោះ។

-ជនជាប់ចោទឈ្មោះ [redacted] NG YONG QING បាននិយាយសំដីចុងក្រោយបង្អស់ថា ចំពោះរឿងនេះខ្លួនស្នើសុំឱ្យតុលាការជួយបន្ធូរបន្ថយទោសដល់រូបខ្លួនផង។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទឈ្មោះ [redacted] NG YONG QING

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] BIN និងឈ្មោះ [redacted] DAO QIANG

-ក្រោយពីបានស្តាប់ចម្លើយសាក្សីជាមន្ត្រីនគរបាលយុត្តិធម៌ឈ្មោះ [redacted] ហុងងួន

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

សំអាងហេតុ

១-តុលាការបានទទួលសំណុំរឿងព្រហ្មទណ្ឌលេខ ៥១00 ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៣ មកជំនុំជម្រះតាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៥៧៦៥ "ក" ដ.ដ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ លើជនជាប់ចោទទី១.ឈ្មោះ [redacted] NG YONG QING ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិសិង្ហបុរី ពីបទ: ឆបោក ប្រព្រឹត្តនៅចំណុចសណ្ឋាគារ NAGA2 បន្ទប់លេខ១២២៩ ជាន់ទី១២ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន

Scanned with CamScanner

រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ និងថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ និង២.ឈ្មោះ [redacted] DAO QIANG ភេទប្រុស អាយុ៤៤ឆ្នាំ ជនជាតិចិន និង៣.ឈ្មោះ [redacted] BIN ភេទប្រុស អាយុ៣៩ឆ្នាំ ជនជាតិចិន ពីបទ: ចាប់បង្ខាំងមនុស្សដោយខុសច្បាប់ ប្រព្រឹត្តនៅចំណុចសណ្ឋាគារNAGA2 បន្ទប់លេខ១២២៩ ជាន់ទី១២ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ និងថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៥៣ នៃក្រមព្រហ្មទណ្ឌ។

២-កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ កម្លាំង(HOTLINE)ជាមួយជនបរទេសនៃនាយកដ្ឋានចារកម្មនៃអគ្គស្នងការដ្ឋាននគរបាលជាតិ បានទទួលបណ្តឹងតាមទូរស័ព្ទមកក្រុមការងារ CNP-GDI-FBI-Task Force ពីក្រុមគ្រួសារជនរងគ្រោះឈ្មោះ [redacted] NG YONG QING ភេទប្រុស អាយុ២៨ឆ្នាំ ជាជនជាតិសិង្ហបុរី សង្ស័យចាប់ជំរិតនៅប្រទេសកម្ពុជា ទើបសមត្ថកិច្ចបានសហការជាមួយនាយកដ្ឋានល្បែងពាណិជ្ជកម្មនៃអគ្គស្នងការដ្ឋាននគរបាលជាតិ បានចុះស្រាវជ្រាវ កំណត់ទីតាំងនៅសណ្ឋាគារ NAGA2 បន្ទប់លេខ១២២៩ ជាន់ទី១២ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ នៅវេលាម៉ោង ១០ និង ០០ នាទីយប់ ហើយសមត្ថកិច្ចបានរកឃើញឈ្មោះ [redacted] NG YONG QING ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិសិង្ហបុរី ឈ្មោះ [redacted] BIN ភេទប្រុស អាយុ៣៩ឆ្នាំ ជនជាតិចិន និងឈ្មោះ [redacted] DAO QIANG ភេទប្រុស អាយុ៤៣ឆ្នាំ ជនជាតិចិន តែម្តង។

៣-ជនជាប់ចោទឈ្មោះ [redacted] NG YONG QING បានឆ្លើយសារភាពថា: ខ្លួនបានមកប្រទេសកម្ពុជា ហើយបានចូលលេងល្បែងនៅណាហ្គា២ ដោយបានបង្ហាញគណនីគ្រីបតូដែលមានទឹកប្រាក់ចំនួន ៤៥.០០០$ ហើយខ្លួនក៏បានលេងល្បែងនៅក្នុងណាហ្គានេះរហូតចាញ់ប្រាក់អស់ចំនួន ៥០.០០០$។ បន្ទាប់មកខាងណាហ្គា២បានយកគ្រីបតូទៅទូទាត់ ស្រាប់តែនៅក្នុងគណនីនេះពុំមានទឹកប្រាក់ ហើយខ្លួនពុំបានដឹងថាខាងណាហ្គាតម្រូវឱ្យខ្លួនបង់ប្រាក់ជាមុនទេ។ ដោយសារនៅក្នុងគណនីគ្រីបតូនោះពុំមានសាច់ប្រាក់ ទើបខាងណាហ្គាមិនអោយខ្លួនចេញ ហើយខ្លួនក៏បានបញ្ជាក់ថា ខ្លួនពុំមានចេតនាគេចវេះអ្វីទេ បើមានលុយខ្លួននឹងសងឱ្យខាងណាហ្គាវិញហើយ។

៤-តាមអំណាចឆ្លើយជនជាប់ចោទឈ្មោះ [redacted] DAO QIANG បានបញ្ជាក់ថា: ខ្លួនពិតជាបានឃាត់ខ្លួនឈ្មោះ [redacted] NG YONG QING មែនដោយសារឈ្មោះ [redacted] NG YONG QING បានលេងល្បែងចាញ់ ហើយពុំបានសងប្រាក់មកខាងកាស៊ីណូណាហ្គា២។ ឈ្មោះ [redacted] NG YONG QING បានចូលមកលេងល្បែងដោយបង្ហាញគណនីគ្រីបតូមានទឹកប្រាក់ចំនួន ៤៥.០០០$ ទើបខាងកាស៊ីណូណាហ្គា២ឱ្យប្រាក់ទៅឈ្មោះ [redacted] NG YONG QING លេង ហើយឈ្មោះ [redacted] NG YONG QING លេងចាញ់ល្បែងអស់។ ដល់ពេលឆែកមើលគណនីគ្រីបតូពុំមានសាច់ប្រាក់ ហើយឈ្មោះ [redacted] NG YONG QING ចង់រត់គេចខ្លួនថែមទៀត ទើបខ្លួនឃាត់ខ្លួនតែម្តង។ មូលហេតុនៃការឃាត់ខ្លួនឈ្មោះ [redacted] NG YONG QING ដោយសារចង់ឱ្យឈ្មោះ [redacted] NG YONG QING សងប្រាក់មកខាងកាស៊ីណូណាហ្គា២ វិញតែប៉ុណ្ណោះ ហើយខ្លួនក៏ពុំបានធ្វើបាប ឬប្រើហិង្សាអ្វីដែរ ហើយខ្លួនឃាត់ឈ្មោះ [redacted] NG YONG QING មិនដល់២៤ម៉ោងទេ។

៥-តាមអំណាចឆ្លើយជនជាប់ចោទឈ្មោះ [redacted] BING បានបញ្ជាក់ថា: ខ្លួន និងឈ្មោះ [redacted] DAO QIANG គឺជាបុគ្គលិកកាស៊ីណូណាហ្គា២ ទទួលប្រាក់ខែចំនួន ១.៣០០$ ក្នុងមួយខែ។ មូលហេតុដែលខ្លួនឃាត់ឈ្មោះ [redacted] NG YONG QING ព្រោះឈ្មោះ [redacted] NG YONG QING លេងល្បែងចាញ់អស់ប្រាក់ចំនួន ៥០.០០០$ មិនព្រមសង និងព្យាយាមរត់គេចខ្លួនមិនទទួលខុសត្រូវថែមទៀត។ ឈ្មោះ [redacted] NG YONG QING បានចូលលេងល្បែងនៅកាស៊ីណូណាហ្គា២ ដោយបង្ហាញគណនីគ្រីបតូមានទឹកប្រាក់ចំនួន ៤៥.០០០$ ហើយខាងណាហ្គាក៏អនុញ្ញាតឱ្យលេង ដល់ពេលលេងចាញ់

អស់មិនព្រមសងប្រាក់ ហើយប្រុងរត់គេចខ្លួនទៀត ទើបពួកខ្លួនឃាត់ខ្លួនឈ្មោះ [redacted] NG YONG QING តែម្តង។ ពួកខ្លួនពុំបានវាយដំ ឬឃុំឃាំង ឬប្រើហិង្សាទៅលើឈ្មោះ [redacted] NG YONG QING នោះទេ ដោយសារខ្លាចឈ្មោះ [redacted] NG YONG QING រត់គេចខ្លួនពុំព្រមសងប្រាក់។

៦-សាក្សីឈ្មោះ [redacted] ហុងងួន ជាមន្ត្រីនគរបាលយុត្តិធម៌បានឆ្លើយថា: ឈ្មោះ [redacted] NG YONG QING ភេទប្រុស និងមិត្តភក្តិពីរនាក់ទៀតឈ្មោះ តាន់គីមយុង និងឈ្មោះ អៀណេស ចូលមកប្រទេសកម្ពុជា ហើយបានចូលលេងល្បែងនៅណាហ្គា២ បើឈ្នះនឹងចែកភាគលាភចំនួន៥0%។ នៅលើកទីមួយឈ្មោះ [redacted] NG YONG QING បានឈ្នះ និងបានត្រឡប់ទៅវិញ។ ក្រោយមកឈ្មោះ អៀណេស បានប្រាប់ទៅឈ្មោះ [redacted] NG YONG QING ឱ្យមកម្តងទៀត ដោយមកជាមួយបុគ្គលពីរនាក់ផ្សេងទៀត ហើយក៏បានមកដល់ប្រទេសកម្ពុជា ដោយប្រើគណនីគ្រីបតូដើម្បីខ្ចីប្រាក់ចំនួន ៥0.000$ ហើយបង្ហាញទៅខាងណាហ្គាគេឱ្យខ្ចីប្រាក់ហើយ។ នៅពេលនោះឈ្មោះ [redacted] NG YONG QING បានបង្ហាញគណនីទៅខាងណាហ្គាមើលគេក៏ឱ្យខ្ចី និងលេងល្បែងនៅណាហ្គាស្រាប់តែចាញ់អស់ ហើយបានទាក់ទងទៅឈ្មោះ អៀណេស ប៉ុន្តែទាក់ទងមិនបាន ហើយបានទាក់ទងទៅឈ្មោះ [redacted] ទៀត ស្រាប់តែឈ្មោះ ជែក បានប្រាប់ឈ្មោះ [redacted] NG YONG QING ឱ្យរត់ចេញទៅ។ ដល់ពេលរត់គេចខ្លួនស្រាប់តែមិត្តភក្តិពីរនាក់ទៀតបានរត់គេចខ្លួនបាត់ ហើយឈ្មោះ [redacted] NG YONG QING ត្រូវបានខាងក្រុមហ៊ុនចាប់ខ្លួនជាប់។ បន្ទាប់មកខាងក្រុមហ៊ុនបានប្រាប់ទៅឈ្មោះ [redacted] NG YONG QING ឱ្យទាក់ទងទៅក្រុមគ្រួសារគាត់ តែបែរជាប្រាប់ថា “គេចាប់ជិវិតគាត់ទៅវិញ”។ ពេលសមត្ថកិច្ចចុះទៅកន្លែងកើតហេតុនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២0២៣ បាននាំខ្លួនឈ្មោះ [redacted] NG YONG QING មកសួរនាំទើបដឹងថា “តាមពិតគាត់ចូលទៅលេងនៅកាស៊ីណូលេងល្បែងចាញ់អត់មានលុយសង ហើយមិត្តភក្តិគាត់បានកុហក ទើបគាត់ព្យាយាមរត់គេចខ្លួន”។ សមត្ថកិច្ចក៏បានកសាងសំណុំរឿង និងចោទប្រកាន់ទៅលើឈ្មោះ [redacted] NG YONG QING ពីបទ: ឆបោក ដែរ។ ចំពោះករណីចាប់បង្ខាំងមនុស្សដោយខុសច្បាប់វិញគឺពេលចុះទៅឈ្មោះ [redacted] NG YONG QING សម្ងំធម្មតា រីឯពីរនាក់ទៀតឈ្មោះ ZHANG BIN និងឈ្មោះ [redacted] DAO QIANG គេងនៅលើគ្រែធម្មតាព្រោះជាកន្លែងស្នាក់នៅ។ ដោយសារឈ្មោះ [redacted] NG YONG QING មានមុខរបួស ហើយឈ្មោះ [redacted] NG YONG QING បានប្រាប់ថា “មានគេវៃគាត់” ប៉ុន្តែឈ្មោះ CHEN DAO QIANG បញ្ជាក់ថានៅពេលដែលឈ្មោះ [redacted] NG YONG QING ព្យាយាមរត់គេចខ្លួនគឺមានការប្រតាយប្រតប់គ្នាបានជាមានរបួសស្នាម ហើយឈ្មោះ [redacted] NG YONG QING បានថតរបួសស្នាមនេះផ្ញើទៅក្រុមគ្រួសារខ្លួនហើយប្រាប់ថា “មានការចាប់ជិវិតគាត់”។ ចំពោះរបួសស្នាមរបស់ឈ្មោះ [redacted] NG YONG QING នេះគឺកើតឡើងដោយសារមានការប្រតាយប្រតប់គ្នាខណៈពេលឈ្មោះ [redacted] NG YONG QING ព្យាយាមរត់គេចខ្លួន។

៧-តាមរបាយការណ៍សំយោគលេខ ១00៩/២៣ រ.ប.ក ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២0២៣ របស់នាយកដ្ឋានចារកម្មនៃអគ្គស្នងការដ្ឋាននគរបាលជាតិ បានសន្និដ្ឋានថា ជនជាប់ចោទឈ្មោះ [redacted] NG YONG QING សង្ស័យពាក់ព័ន្ធនឹងអំពើឆបោកដោយខ្លួនគ្មានប្រាក់ តែបែរជាមកលេងល្បែងក្នុងកាស៊ីណូ។ ចំណែកឈ្មោះ [redacted] BIN និងឈ្មោះ [redacted] DAO QIANG សង្ស័យធ្វើការបង្ខាំង និងបង្ខំគំរាមឈ្មោះ [redacted] NG YONG QING ដើម្បីសងប្រាក់លើសពីគោលការណ៍ក្រុមហ៊ុនពិតប្រាកដមែន។

៨-តាមចម្លើយរបស់ជនជាប់ចោទ និងសាក្សី ព្រមទាំងឯកសារជាភស្តុតាងនានាក្នុងសំណុំរឿងមានលក្ខណៈស៊ីសង្វាក់បញ្ជាក់ថា ជនជាប់ចោទឈ្មោះ [redacted] NG YONG QING ភេទប្រុស កើតថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៥ ពិតជាប្រព្រឹត្តន្ទវអំពើ ឆបោក ដោយបានប្រើឧបាយកលទុច្ចរិតបង្ហាញគណនីគ្រីបតូដើម្បីឱ្យក្រុមហ៊ុនប្រគល់កាក់ឱ្យខ្លួន ជាក់ស្តែងគណនីពុំ

មានសាច់ប្រាក់នោះទេ ប្រព្រឹត្តនៅចំណុចសណ្ឋាគារណាហ្គា២ បន្ទប់លេខ១២២៩ ជាន់ទី១២ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ និងថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧ និង៣៧៨ នៃក្រមព្រហ្មទណ្ឌ ប្រាកដមែន។ រីឯឈ្មោះ [redacted] BIN អាទប្រុស និងឈ្មោះ [redacted] DAO QIANG អាទប្រុស ពិតជាបានប្រព្រឹត្តនូវអំពើ ចាប់បង្ខាំងមនុស្សដោយខុសច្បាប់ ប្រព្រឹត្តនៅចំណុចសណ្ឋាគារណាហ្គា២ បន្ទប់លេខ១២២៩ ជាន់ទី១២ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៥៣ នៃក្រមព្រហ្មទណ្ឌ។

៩-សកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] NG YONG QING អាទប្រុស ដែលបានបង្ហាញគណនីគ្រីបតូទៅភាគីក្រុមហ៊ុនកាស៊ីណូណាហ្គាដើម្បីទទួលបានប្រាក់លេងល្បែង ហើយនៅពេលខាងក្រុមហ៊ុនដែកមើលគណនីគ្រីបតូពុំមានសាច់ប្រាក់ ហើយជនជាប់ចោទលេងល្បែងចាញ់និងមានចេតនាគេចវេសមិនព្រមសង និងព្យាយាមរត់គេចខ្លួនថែមទៀតធ្វើឱ្យបាត់បង់ផលប្រយោជន៍ជនរងគ្រោះ ត្រូវបានច្បាប់កំណត់ថាជាបទល្មើស **ឆបោក** បញ្ញត្តិឱ្យផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ)ខែ ទៅ ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី ១.000.000 (មួយលាន)រៀល ទៅ ៦.000.000 (ប្រាំមួយលាន)រៀល តាមមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ។ ដោយឡែកចំពោះជនជាប់ចោទឈ្មោះ [redacted] BIN និងឈ្មោះ CHEN DAO QIANG ដែលបានធ្វើសកម្មភាពបង្ខាំងលើជនជាប់ចោទឈ្មោះ [redacted] NG YONG QING ដើម្បីឱ្យជនជាប់ចោទឈ្មោះ [redacted] NG YONG QING សងប្រាក់ដែលមានរយៈពេលតិចជាង៥៨(សែសិបប្រាំបី)ម៉ោង ត្រូវបានច្បាប់កំណត់ថាជាបទល្មើស ចាប់បង្ខាំងមនុស្សដោយខុសច្បាប់ បញ្ញត្តិឱ្យផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំ ទៅ ៣(បី)ឆ្នាំ តាមមាត្រា ២៥៣ ចំណុចទី១ នៃក្រមព្រហ្មទណ្ឌ។

១០-អំពើរបស់ជនជាប់ចោទធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ជនរងគ្រោះ ហើយជនជាប់ចោទមានសមត្ថភាពស្មារតីគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត និងយល់ដឹងពីផលវិបាកដែលកើតចេញពីអំពើរបស់ខ្លួនដែលស្ថិតនៅក្នុងលក្ខខណ្ឌនៃការខុសត្រូវច្បាប់ព្រហ្មទណ្ឌ។

១១-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋាននាពេលសវនាការថា: មានមូលដ្ឋានគ្រប់គ្រាន់ដើម្បីបញ្ជាក់ពីតម្រុយពិរុទ្ធភាពរបស់ជនជាប់ចោទឈ្មោះ [redacted] NG YONG QING ពីបទ: ឆបោក តាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ និងឈ្មោះ [redacted] BIN និងឈ្មោះ [redacted] DAO QIANG ពីបទ: ចាប់បង្ខាំងមនុស្សដោយខុសច្បាប់ តាមបញ្ញត្តិមាត្រា ២៥៣ នៃក្រមព្រហ្មទណ្ឌ មានលក្ខណៈត្រឹមត្រូវតាមច្បាប់។

១២-ការលើកឡើងរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] BIN និងឈ្មោះ [redacted] DAO QIANG សន្និដ្ឋានថា: ស្នើសុំឱ្យតុលាការឱ្យកូនក្តីខ្លួនរួចផុតបទចោទប្រកាន់ តប្បីតុលាការមិនលើកយកមកពិចារណាដោយហេតុថាជនជាប់ចោទឈ្មោះ [redacted] BIN អាទប្រុស និងឈ្មោះ [redacted] DAO QIANG អាទប្រុស បានឆ្លើយសារភាពថាពួកខ្លួនគឺបានឃាត់ខ្លួនឈ្មោះ [redacted] NG YONG QING ដើម្បីឱ្យឈ្មោះ [redacted] NG YONG QING សងប្រាក់មកឱ្យខាងក្រុមហ៊ុនណាហ្គា២ ហើយឈ្មោះ [redacted] NG YONG QING ព្យាយាមគេចខ្លួនប្រាកដមែន ប៉ុន្តែពួកខ្លួនមិនវាយអ៊ុំអ្វីទេ។

១៣-ការលើកឡើងរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] NG YONG QING សន្និដ្ឋានថា: ស្នើសុំឱ្យតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនផង តប្បីតុលាការនឹងលើកយកមកពិចារណាព្រោះជនជាប់ចោទបានឆ្លើយសារភាពអំពើប្រព្រឹត្តរបស់ខ្លួន។

១៤-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] NG YONG QING ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិសិង្ហបុរី ពីបទ: **រាបោក** ប្រព្រឹត្តនៅចំណុចសណ្ឋាគារNAGA2 បន្ទប់លេខ១២២៩ ជាន់ទី១២ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ និងថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ។

១៥-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] BIN ភេទប្រុស អាយុ៣៩ឆ្នាំ ជនជាតិចិន និងឈ្មោះ CHEN DAO QIANG ភេទប្រុស អាយុ៤៤ឆ្នាំ ជនជាតិចិន ពីបទ: ចាប់បង្ខាំងមនុស្សដោយខុសច្បាប់ ប្រព្រឹត្តនៅចំណុចសណ្ឋាគារNAGA2 បន្ទប់លេខ១២២៩ ជាន់ទី១២ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ និងថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៥៣ ចំណុចទី១ នៃក្រមព្រហ្មទណ្ឌ។

១៦-ជនជាប់ចោទឈ្មោះ [redacted] NY YONG QING ភេទប្រុស បានប្រព្រឹត្តអំពើធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់និងរបៀបរៀបរយសាធារណៈ បង្កឱ្យមានព្យសនៈកម្មយ៉ាងធ្ងន់ធ្ងរដល់សង្គម និងសន្តិសុខជាតិនៃព្រះរាជាណាចក្រកម្ពុជា អ្វីចនេះគប្បីផ្តន្ទាទោសទ្វេរទោសបន្ថែមដោយហាមឃាត់ចំពោះការចូល និងការស្នាក់លើដែនដីព្រះរាជាណាចក្រកម្ពុជាដោយកំណត់រយៈពេល៥(ប្រាំ)ឆ្នាំ ក្រោយអនុវត្តទោសរួច ស្របតាមមាត្រា ៥៣ ចំណុចទី៧ មាត្រា ៦១ និងមាត្រា ២៥៥ នៃក្រមព្រហ្មទណ្ឌ។

១៧-យោងតាមកំណត់ហេតុទទួលវត្ថុចាប់យក(០១)លេខ ១៥៦៦ រ.ស.ត ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញជាវត្ថុដែលមិនពាក់ព័ន្ធនឹងបទល្មើស គប្បីសម្រេចប្រគល់ឱ្យម្ចាស់វិញមានអ្វីចជា: ទូរស័ព្ទដៃម៉ាក SAMSUNG ពណ៌ប្រផេះ ចំនួនមួយគ្រឿង(មិនដំណើរការ) និង លិខិតឆ្លងដែនប្រទេសសិង្ហបុរី(PASSPORT REPUBLIC OF SINGAPORE) ចំនួនមួយក្បាលមានឈ្មោះ [redacted] NG YONG QING។

១៨-តុលាការនឹងប្រកាសទោសដាក់ពន្ធនាគារអប្បរមានៃទោសចំពោះជនជាប់ចោទឈ្មោះ [redacted] G BIN ភេទប្រុស និងឈ្មោះ [redacted] DAO QIANG ភេទប្រុស តុលាការនឹងពិចារណាក្នុងការប្រកាសឱ្យព្យួរទោសធម្មតា ដើម្បីទុកឱកាសឱ្យជនជាប់ចោទបានកែប្រែខ្លួន ដោយជនជាប់ចោទបានសារភាពទ្វេរទោសកំហុសរបស់ខ្លួន ហើយជនជាប់ចោទទើបតែប្រព្រឹត្តបទល្មើសដែលត្រូវតុលាការផ្តន្ទាទោសជាលើកទី១ ហើយទោសដែលប្រកាសនេះមិនមានរយៈពេលលើសពី ៥(ប្រាំ)ឆ្នាំ យោងតាមមាត្រា ១០៤ ដល់មាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌ។

ហេតុដូច្នេះ សម្រេច

១-ផ្តន្ទាទោស៖

ក-ឈ្មោះ [redacted] NG YONG QING ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិសិង្ហបុរី(ដែលមានសាវតាជាតិអ្វីចខាងលើ) ដាក់ពន្ធនាគារកំណត់ ៨(ប្រាំបី)ខែ ពីបទ: រាបោក ប្រព្រឹត្តនៅចំណុចសណ្ឋាគារ NAGA2 សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ និងថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ។

ខ-ទោសបន្ថែមលើឈ្មោះ [redacted] NG YONG QING ភេទប្រុស ដោយហាមឃាត់ចំពោះការចូល និងការស្នាក់លើដែនដីនៃព្រះរាជាណាចក្រកម្ពុជារយៈពេល៥ឆ្នាំ ក្រោយអនុវត្តទោសរួច តាមបញ្ញត្តិមាត្រា ៥៣ ចំណុចទី៧ មាត្រា ៦១ និងមាត្រា ២៥៥ នៃក្រមព្រហ្មទណ្ឌ។

Scanned with CamScanner

គ-ឈ្មោះ [redacted] BIN ភេទប្រុស អាយុ៣៩ឆ្នាំ ជនជាតិចិន(ដែលមានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់ ១(មួយ)ឆ្នាំ ទោសពន្ធនាគារត្រូវអនុវត្តជារយៈពេលឃុំខ្លួនជាបណ្តោះអាសន្ន ទោសដែលនៅសល់ត្រូវប្តូរការអនុវត្តតាមបញ្ញត្តិមាត្រា ១០៤ ដល់មាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌ។

ឃ-ឈ្មោះ [redacted] DAO QIANG ភេទប្រុស អាយុ៤៤ឆ្នាំ ជនជាតិចិន(ដែលមានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់ ១(មួយ)ឆ្នាំ ទោសពន្ធនាគារត្រូវអនុវត្តជារយៈពេលឃុំខ្លួនជាបណ្តោះអាសន្ន ទោសដែលនៅសល់ត្រូវប្តូរការអនុវត្ត តាមបញ្ញត្តិមាត្រា ១០៤ ដល់មាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌ។

ពីបទ: ចាប់បង្ខាំងមនុស្សដោយខុសច្បាប់ ប្រព្រឹត្តនៅចំណុចសណ្ឋាគារNAGA2 បន្ទប់លេខ១២២៩ ជាន់ទី១២ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ និងថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៥៣ ចំណុចទី១ នៃក្រមព្រហ្មទណ្ឌ។

២-ប្រគល់ឱ្យម្ចាស់ដើមឈ្មោះ [redacted] NG YONG QING រួមមាន: ទូរស័ព្ទដៃម៉ាក SAMSUNG ពណ៌ប្រផេះ ចំនួនមួយគ្រឿង(មិនដំណើរការ) និង លិខិតឆ្លងដែនប្រទេសសិង្ហបូរី(PASSPORT REPUBLIC OF SINGAPORE) ចំនួនមួយក្បាលមានឈ្មោះ [redacted] NG YONG QING។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៤ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៤ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] NG YONG QING ភេទប្រុស និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] BIN ភេទប្រុស និងឈ្មោះ [redacted] DAO QIANG ភេទប្រុស។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

ត្រឡាចញ៉ីសវនាការ

ហត្ថលេខា និងត្រា

[redacted]

ចៅក្រមជំនុំជម្រះ

ហត្ថលេខា និងត្រា

[redacted]

បានឃើញ

ចៅក្រមជំនុំជម្រះ

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ៥កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៤

ត្រឡាចញ៉ី

[redacted]

Scanned with CamScanner